គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

# សេចក្តីជូនដំណឹង

**គណៈកម្មាធិការ ខុមហ្វ្រែល** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក លោកស្រី នាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ មេត្តាជ្រាបថា គណៈកម្មាធិការ ខុមហ្វ្រែល នឹងមានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតស្តីពី "**ការកំណត់តម្រូវការជាអាទិភាពនៅឃុំ សង្កាត់ដាច់ស្រយាល**" ចំនួន ០៦ នៅតាមទីកន្លែងដោយឡែកៗពីគ្នា។

សិក្ខាសាលានេះ មានគោលបំណង បង្កើនការយល់ដឹងដល់ម្ចាស់ឆ្នោតអំពីសិទ្ធិ តួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោត ក្នុងការអភិវឌ្ឍន៍នៅមូលដ្ឋាន និងបង្កើនឱកាសឱ្យម្ចាស់ឆ្នោតចូលរួមក្នុងការពិភាក្សាដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ សង្កាត់របស់ខ្លួន ហើយតម្រូវការជាអាទិភាពទាំងនេះ នឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សា ឃុំ សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សក្នុងឃុំ។

ខុមហ្វ្រែល នឹងអញ្ជើញវាគ្មិនជាក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងតំណាងអង្គការសង្គមស៊ីវិល ឬប្រធានសហគមន៍ដើម្បីចាប់អារម្មណ៍ទៅលើតម្រូវការជាអាទិភាពក្នុងឃុំ សង្កាត់ដែលបានលើកឡើងដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ សម្រាប់ផ្តល់ជូនគណបក្សនយោបាយ និងមន្ត្រីជាប់ឆ្នោតបំពេញ។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញដល់លោក លោកស្រី នាងកញ្ញាតំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។

## ទីកន្លែង និងកាលបរិច្ឆេទ សិក្ខាសាលាសម្លេងម្ចាស់ឆ្នោត

| ល.រ | ថ្ងៃខែឆ្នាំរៀបចំ | ឃុំ/សង្កាត់ | ក្រុង/ស្រុក/ខណ្ឌ | រាជធានី/ខេត្ត | ឈ្មោះទំនាក់ទំនង | ទូរសព្ទ |
|---|---|---|---|---|---|---|
| ១ | ២៥/០៤/២០១១ | បឹងចារ | សំបូរ | ក្រចេះ | អ្នកស្រី **អ៊ឹម ម៉ានី** | ០៩២ ៥៨២ ៦៧៨ |
| ២ | ២៧/០៤/២០១១ | អូរគ្រៀង | | | | |
| ៣ | ២៦/០៤/២០១១ | ភ្នីមាស | គិរីសាគរ | កោះកុង | កញ្ញា **ស៊ី សុគន្ធា** | ០១៦ ៧៣០ ៩៩៣ |
| ៤ | ២៨/០៤/២០១១ | ជ្រោយប្រស់ | កោះកុង | | | |
| ៥ | ២៦/០៤/២០១១ | ព្រែកណ្តៀង | ពាមរក៍ | ព្រៃវែង | លោក **គឹម សុខុម** | ០១៦ ៩៥៩ ២៦៥ |
| ៦ | ២៩/០៤/២០១១ | កោះសំពៅ | ពាមជរ | | | |

*សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់ !*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១*

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖** លោកស្រី ៖ **ហេង សុគន្ធា** (០១៧ ៥៨៣ ៨៦៩)

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Central Office** : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org